# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១៤ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០៥ រូប ជាទីប្រឹក្សា និង ជាជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ៤០០

១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១៥ ស្តីពី ការតែងតាំងឯកឧត្តម **យី ឆន់** ជាទីប្រឹក្សាសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤០២

១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១៧ ស្តីពី ការតែងតាំងឯកឧត្តម Philippe COSTE ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី ៤០៣

១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០២៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូនឯកឧត្តម **សយ សុខាន់** ពីវរមន្ត្រី ថ្នាក់លេខ ៤ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រង រដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ៤០៤

១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០២៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០៧ រូប ៤០៥

១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០២៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **អ៊ូ មុនីរ័ត្ន** នាយនគរបាលជាតិជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៤០៧

១៤-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០៣៩ ស្តីពី ការតែងតាំងលោក **អ៊ុំ ស៊ីតាតថិរៈ** ជា ឧកញ៉ា ៤០៨

១៤-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា **សំ អាង** ៤០៩

១៤-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០៤២ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ នាយឧត្តមសេនីយ៍ ជាកិច្ចបច្ឆាមរណៈ ជូនសពឧត្តមសេនីយ៍ឯក **មស់ ភឿម** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៤១០


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៦-០១-២០១២ -អនុក្រឹត្យលេខ ៤៥ អនក្រ.គត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១១

១៦-០១-២០១២ -អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៤១២

១៦-០១-២០១២ -អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៣

១៦-០១-២០១២ -អនុក្រឹត្យលេខ ៤៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤១៥

១៦-០១-២០១២ -អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៧

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៨

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៩

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤២១

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥៣ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤២៣

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤២៤

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥៥ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ៤២៦

១៧-០១-២០១២ -អនុក្រឹត្យលេខ ៥៦ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ៤២៧

១៦-០១-២០១២ -អនុក្រឹត្យលេខ ៥៧ អនក្រ.តត ស្ដីពី ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ៤២៨

១៧-០១-២០១២ -អនុក្រឹត្យលេខ ៥៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៤២៩

១៧-០១-២០១២ -អនុក្រឹត្យលេខ ៥៩ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤៣០

១៧-០១-២០១២ -អនុក្រឹត្យលេខ ៦០ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤៣១

១៧-០១-២០១២ -អនុក្រឹត្យលេខ ៦១ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣២

១៧-០១-២០១២ -អនុក្រឹត្យលេខ ៦២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៤៣៤

១៧-០១-២០១២ -អនុក្រឹត្យលេខ ៦៣ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៤៣៥

១៧-០១-២០១២ -អនុក្រឹត្យលេខ ៦៤ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ៤៣៧

១៧-០១-២០១២ -អនុក្រឹត្យលេខ ៦៥ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤៣៩


## ២-សេចក្ដីសម្រេច


១៣-០១-២០១២-សេចក្ដីសម្រេចលេខ ០៤ សសរ ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយករណីកម្មករ កម្មការិនី ដួលសន្លប់ នៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើង ៤៤០


## III-ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២៤-១១-២០១០ -លិខិតបញ្ជាក់លេខ ៩៣៣៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អារក្រោ ខេន ផ្លេនថេសិន** ៤៤៣

២៤-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៤៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វុង យ៉េន ជី គ្រេឌីង** ៤៤៥

២៤-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេសឌីខេភី រីសេសស៍** ៤៤៧

២៤-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ផៅឌ័រ អ៊ិនធើរ គ្រេឌីង** ៤៤៩

២៤-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ាឡុងជី អ៊ីមផត អិចផត** ៤៥១

២៥-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៥៩ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ឌីសិនហ្វាន់ (ខេមបូឌា) អិលធីឌី** ៤៥៣

២៥-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សហគ្រាស ផលិត ឥដ្ឋ គ្បឿង អង្គរ** ៤៥៥

២៥-១១-២០១០ - លិខិតបញ្ជាក់លេខ ៥៣៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ានស៊ីធីឌីវ៉េឌីឡាយថ៍គ្រុប** ៤៥៧

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៥៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១១/៣៤០ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលមុខតំណែង សមាសភាពថ្នាក់ដឹកនាំមួយចំនួន នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំង :

១- ឯកឧត្តម **អ៊ុត រឿន** ជា ទីប្រឹក្សាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- ឯកឧត្តម **មុំ សុទ្ធ** ជា ទីប្រឹក្សាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- ឯកឧត្តម **ពុំ ប៊ុនច័ន្ទរ័ត្ន** ជា ជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** ។

៤- ឯកឧត្តម **ម៉ាន់ ប៊ុនឡាយ** ជា ជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** ។

៥- ឯកឧត្តម **អ៊ឹម ប៊ុរិន្ទ** ជា ជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ថរទ. ១២០១.០១៦

លេខ: ២២ ច.ល
**សេចក្តីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១២*

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២
**អគ្គលេខា[illegible]ទីស្តីការរដ្ឋាភិបាល**

**[illegible] សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១៥

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ត្រាស់បង្គាប់

តែងតាំង ឯកឧត្តម **ឃី ឆន់** ជា ទីប្រឹក្សាសម្ដេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១២០១-០១៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២

លេខៈ ៧១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១២
**[illegible]ទីស្ដីទីរាជរដ្ឋាភិបាល**
ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១.-** ត្រូវបានតែងតាំងឯកឧត្តម Philippe COSTE ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១២០១.០១៩

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១២

លេខៈ ២៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១២
**អគ្គលេខាធិការ [illegible] ទីស្តីការរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនឯកឧត្តម **សយ សុខាន់** ពី វរមន្ត្រី ថ្នាក់លេខ ៤ ទៅ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧-១២០១-០២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២

ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០២៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ចំនួន **០៧រូប** នៃក្រសួងមហាផ្ទៃ :

១-លោកវរសេនីយ៍ឯក **ឃួន សុផល្លី** អត្តលេខ ៣២៣២៨
២-លោកវរសេនីយ៍ឯក **ឈូក ស្រូគុំ** អត្តលេខ ៣២៣២៧
៣-លោកវរសេនីយ៍ឯក **ជ័យ ជាតិ** អត្តលេខ ១២៦៦១
៤-លោកវរសេនីយ៍ឯក **យី សិទ្ធិ** អត្តលេខ ០៥១០៨

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៥-លោកវរសេនីយ៍ឯក **ម៉ោង ចំនួនជាវ៉ា** អត្តលេខ ០៨៣២៨

៦-លោកវរសេនីយ៍ឯក **សេក វង្សា** អត្តលេខ ០១១៧១

៧-លោកវរសេនីយ៍ឯក **ឈឹម នាង** អត្តលេខ ៣២៣៦៣

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកត.១២០១.០៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២

លេខៈ [illegible] ច.ល

**ដើម្បីចម្លងចេញ**

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១២

**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០២៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្ដមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **អ៊ុំ មុនីរត្ន** អត្តលេខ ១២៩៧៣ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩. ១២០១. ០៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

លេខៈ ៧៤ ច.ល
[illegible]ចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible]ជា

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០៣៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

តែងតាំង

លោក **អ្វ៊ី ស្វ៊ីតាតចិរៈ**

ជា

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស.១២០១.០៤៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១២

លេខ: ៤៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១២
[illegible]ស្តីរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

ឧកញ៉ា **សំ អាង**

មានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាងនូវសមិទ្ធផលនានាជាច្រើន
ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៤.១២០១.០៤៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២*

លេខៈ ៤៩ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១២
[illegible]ការរងទី១រាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០៤៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ថ្នាក់ នាយឧត្តមសេនីយ៍ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

- ឧត្តមសេនីយ៍ឯក មល់ រៀប អត្តលេខ ០០០០៩៣

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១២០១.០៤៧

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២*

លេខៈ ៣០ ប.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**
**[illegible] សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ លើវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

១-លោក **អៀង សុខុម** មេឃុំអំពិលក្រៅ

២-លោកអនុសេនីយ៍ឯក **ស៊ុច ម៉ារី** អត្តលេខ ០៨៤៥១១ អង្គភាពកងពលតូចអី៧០

៣-លោក **សោម សាម៉ន** នាយករដ្ឋបាលសាលាស្រុកស៊ីធរកណ្តាល

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៦ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជូនអនុសេនីយ៍ទោ **អេង លី** អត្តលេខ ០១២៤១៦ ប្រធានផ្ដល់ទិដ្ឋាការច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី ដែលមានស្នាដៃល្អព្រមទាំងបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗក្នុងវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ លើវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិៈ**

| | | | |
|---|---|---|---|
| ១-លោក | **នួន** | **នឿន** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២-លោក | **សេខ** | **សុផល** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣-ឧបាសិកា | **ឃុន** | **សេខតាំងអ៊ីម** | សប្បុរសជននៅប្រទេសបារាំង |
| ៤-អ្នកស្រី | **អ៊ុន** | **ឋារណា** | សប្បុរសជននៅសហរដ្ឋអាមេរិក |
| ៥-លោកអាចារ្យ | **នៃម** | **ខុច** | អាចារ្យវត្តពានា |

**ខ-មេដាយប្រាក់ស្ថាបនាជាតិៈ**

| | | | |
|---|---|---|---|
| ១-លោកអាចារ្យ | **ហាន** | **ស៊ាន** | អាចារ្យវត្តពានា |
| ២-លោកអាចារ្យ | **ហេង** | **ហ៊ឹម** | អាចារ្យវត្តពានា |
| ៣-លោកអាចារ្យ | **តិល** | **ទុំ** | អាចារ្យវត្តពានា |
| ៤-លោក | **ដាន់** | **យឹម** | គណៈកម្មការវត្តពានា |
| ៥-លោក | **ចាន់** | **ប្រាក់** | គណៈកម្មការវត្តពានា |

៦-លោក អ៊ុត ជា គណៈកម្មការវត្តពានា
៧-លោក អ៊ូច សារ៉េត គណៈកម្មការវត្តពានា
៨-លោក ភួង ឆារី គណៈកម្មការវត្តពានា
៩-លោក ឃិន ឡាន គណៈកម្មការវត្តពានា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ លើវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | ជីវ | ប្រេស | ប្រធានការិយាល័យអន្តរវិស័យ នៃសាលាស្រុកស៊ីធរកណ្តាល |
| ២-លោក | អុក | សំរុទ | អនុប្រធានការិយាល័យផែនការនិងគាំទ្រឃុំ នៃសាលាស្រុកស៊ីធរកណ្តាល |
| ៣-លោកស្រី | ទន់ | ពៅ | អនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុនៃសាលាស្រុកស៊ីធរកណ្តាល |
| ៤-លោក | ឆន | រដ្ឋា | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន នៃសាលាខេត្តព្រៃវែង |
| ៥-លោក | អ៊ិន | សុខា | ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក នៃមន្ទីរសុខាភិបាលខេត្តព្រៃវែង |
| ៦-លោក | ហ៊ុយ | អ៊ិត | អនុប្រធានការិ.ឱសថ និងសុវត្ថិភាពចំណីអាហារ នៃមន្ទីរសុខាភិបាលខេត្តព្រៃវែង |
| ៧-លោក | ម៉ិច | សុខុម | ប្រធានផ្នែកទឹកនោមផ្អែម នៃមន្ទីរសុខាភិបាលខេត្តព្រៃវែង |
| ៨-លោកអនុ.ទោ | គឹម | ខេត | អត្តលេខ ០៤៦៨៣៨ មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងព្រៃវែង |
| ៩-លោកព្រិន្ទបាលទោ | ហុយ | ធីតា | អត្តលេខ ៥៦៦៨៩ អនុប្រធានផ្នែកស្ថិតិនៃសាលាស្រុក |
| ១០-លោកស្រី | ជូ | សំអឿន | ទីប្រឹក្សាកម្មវិធីជាតិ ថ្នាក់ស្រុក នៃសាលាស្រុកស៊ីធរកណ្តាល |

| | | | |
|---|---|---|---|
| ១១-លោកស្រី | **ពិន** | **ញាន** | មន្ត្រីអង្គការ វូមែន |
| ១២-លោក | **គង់** | **សំអាត** | ប្រធានការិយាល័យបរិស្ថាន ស្រុកស៊ីធរកណ្តាល |
| ១៣-លោកអនុ.ទោ | **ពេជ្រ** | **ឌឿន** | អត្តលេខ ០៣៥៧៤៩ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ស្រុកស៊ីធរកណ្តាល |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **ម៉ក់ ឈាន** អនុប្រធានការិយាល័យបឋមសិក្សានៃមន្ទីរអប់រំ យុវជននិងកីឡា ខេត្តព្រៃវែង ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗលើវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តខិណ្ណារាម ភូមិខ្សាច់សរ ឃុំរក្សជ័យ ខេត្តព្រៃវែង ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ លើវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តខិណ្ណារាម ភូមិខ្សាច់សរ ឃុំរក្សជ័យ ខេត្តព្រៃវែង សរុបថវិកាចំនួន ៨៧.៦៤៣ ដុល្លារ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិៈ**

១-អ្នកស្រី ហង្ស ចន្ណា សប្បុរសជននៅរាជធានីភ្នំពេញ
២-លោក ស៊ិន ចំរើន សប្បុរសជននៅរាជធានីភ្នំពេញ
៣-អ្នកស្រី ឈិត សុគន្ធ សប្បុរសជននៅរាជធានីភ្នំពេញ

**ខ-មេដាយប្រាក់ស្ថាបនាជាតិៈ**

១-លោក នូ យ៉ាត គណៈកម្មការវត្តខិណ្ណារាម
២-លោក ញ៉ឹក សាវ៉ាត គណៈកម្មការវត្តខិណ្ណារាម
៣-លោក យ៉ូ អ៊ុច គណៈកម្មការវត្តខិណ្ណារាម
៤-លោក អ៊ីត អ៊ួន គណៈកម្មការវត្តខិណ្ណារាម

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ចំនួន២១រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ លើការងារពង្រឹងនូវកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាមួយអាស៊ាន ជាពិសេសក្នុងការខិតខំប្រឹងប្រែងរៀបចំធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីច្បាប់អាស៊ានលើកទី១៤ (14th ASLOM) និងថ្នាក់រដ្ឋមន្ត្រីក្រសួង យុត្តិធម៌និងអគ្គរដ្ឋអាជ្ញាអាស៊ានលើកទី៨ (8 th ALAWMM) ទទួលបានជោគជ័យល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ និបទិន្ទ:**

| | | | |
|---|---|---|---|
| ១-លោក | ឆាន់ | ស៊ីណា | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ២-លោក | ឡុច | សុខលៀង | អធិការ |
| ៣-លោក | ស៊ឹម | សារ៉ាត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ៤-លោកស្រី | សរ | ច័ន្ទរ៉ាត | អនុប្រធាននាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ៥-លោក | សុខ | ម៉ូរ៉ា | អនុប្រធាននាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ៦-លោកស្រី | សៀង | ហ៊ុន | ប្រធានការិយាល័យគ្រឿងឥស្សរិយយស |
| ៧-លោក | ញៀម | ចន្ទរ៉េត | |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

| | | | |
|---|---|---|---|
| ១-លោក | ស៊ី | ពិសេដ្ឋ | អនុប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ២-លោក | ឡុង | មេសា | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី |
| ៣-លោកស្រី | សួរ | ដានី | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |
| ៤-លោកស្រី | យុន | ចាន់សោភា | ប្រធានការិយាល័យកិច្ចការច្បាប់អន្តរជាតិ |

**គ-មេជាយមុនីសារាគំណួ ថ្នាក់ អស្សបុទ្ធិ:**

| | | | |
|---|---|---|---|
| ១-លោក | ម៉ៅ | គុយលីម | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ២-លោក | ម៉េង | គួង | អនុប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៣-លោក | ចេង | គីមហ៊ាង | អនុប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ៤-លោក | សៀង | ហ៊ី | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |
| ៥-លោកស្រី | ម៉ឹង | សំយាន | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល |
| ៦-លោក | ជា | សំបូរ | ប្រធានការិយាល័យព័ត៌មានវិទ្យា |
| ៧-លោកស្រី | ម៉ាន់ | យ៉ានីន | ប្រធានការិយាល័យបណ្តុះបណ្តាល និងវាយតម្លៃ |
| ៨-លោក | អ៊ុំ | ចំន្ទ | ប្រធានការិយាល័យរដ្ឋបាល |
| ៩-លោក | កៅ | យឿន | ប្រធានការិយាល័យសន្តិសុខ |
| ១០-លោក | សួង | ម៉េងហុង | |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ចំនួន៣៦រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ លើការងារពង្រឹងនូវកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាមួយអាស៊ាន ជាពិសេសក្នុងការខិតខំប្រឹងប្រែងរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីច្បាប់អាស៊ាន លើកទី១៤ (14th ASLOM) និងថ្នាក់រដ្ឋមន្ត្រីក្រសួង យុត្តិធម៌និងអគ្គរដ្ឋអាជ្ញាអាស៊ានលើកទី៨ (8 th ALAWMM) ទទួលបានជោគជ័យល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ:**

១-លោកស្រី សឿ ចាន់វាសនា ប្រធានការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន

២-លោក ខ៊ែត ជាទុច ប្រធានការិយាល័យកិច្ចការអាស៊ាន

៣-លោកស្រី ស្រេង សុយ៉េត ប្រធានការិយាល័យស្រាវជ្រាវលើវិស័យយុត្តិធម៌

៤-លោក នូ សក្តី ប្រធានការិយាល័យបច្ចេកទេស និងនីតិវិធី

៥-លោកស្រី សារឿន សុពណ៌ ប្រធានការិយាល័យបុគ្គលិក

៦-លោកស្រី សុខុម ហ៊ុនពុទ្ធារី ប្រធានការិយាល័យផែនការ និងអភិវឌ្ឍន៍ធនធានមនុស្ស

៧-លោកស្រី ជុន ចំរើន ប្រធានការិយាល័យបោះពុម្ពផ្សាយ និងទំនាក់ទំនងសាធារណជន

៨-លោក ចេង សុភា ប្រធានការិយាល័យផ្គត់ផ្គង់ និងសារពើភ័ណ្ឌ

៩-លោកស្រី សុគិន វិសាល អនុប្រធានការិយាល័យបណ្តុះបណ្តាល និងវាយតម្លៃ

១០-លោក ញឹម សុធា អនុប្រធានការិយាល័យស្រាវជ្រាវលើវិស័យយុត្តិធម៌

១១-លោក ឡិ ពេជ្រវាសនា អនុប្រធានការិយាល័យកិច្ចការអាស៊ាន

១២-លោក ឃឹម គុនខួន មន្ត្រីគ្រប់គ្រងរដ្ឋបាល
១៣-លោក តាំង សុផា មន្ត្រីគ្រប់គ្រងរដ្ឋបាល
១៤-លោក ពៅ ទិបុល មន្ត្រីគ្រប់គ្រងរដ្ឋបាល

**ខ-មេជាយគ្រាក់ការងារ:**

១-លោក ចេង សុខមាន ប្រធានការិយាល័យគណនេយ្យ
២-លោកស្រី ឃុត ស៊ាងអែ មន្ត្រីគ្រប់គ្រងរដ្ឋបាល
៣-លោក ខិន មុនី មន្ត្រីគ្រប់គ្រងរដ្ឋបាល
៤-លោកស្រី ជាករុណា មន្ត្រីគ្រប់គ្រងរដ្ឋបាល
៥-លោក ធឿន លីណា មន្ត្រីគ្រប់គ្រងរដ្ឋបាល
៦-លោកស្រី សំអឿន ធីតា មន្ត្រីគ្រប់គ្រងរដ្ឋបាល
៧-លោកស្រី ផាន់ ចាន់ណា មន្ត្រីគ្រប់គ្រងរដ្ឋបាល
៨-លោក លី សុវណ្ណ មន្ត្រីគ្រប់គ្រងរដ្ឋបាល
៩-លោកស្រី ហ៊ិន សុភាព មន្ត្រីគ្រប់គ្រងរដ្ឋបាល
១០-លោកស្រី សួន ណារី មន្ត្រីគ្រប់គ្រងរដ្ឋបាល
១១-លោកស្រី លឹម សុផារី មន្ត្រីគ្រប់គ្រងរដ្ឋបាល
១២-លោកស្រី ខិម ច្រាដា មន្ត្រីគ្រប់គ្រងរដ្ឋបាល
១៣-លោក សូ សុខហុង មន្ត្រីគ្រប់គ្រងរដ្ឋបាល
១៤-លោកស្រី ផល សុភាព មន្ត្រីគ្រប់គ្រងរដ្ឋបាល

**គ-មេជាយសិទ្ធិការងារ:**

១-លោក ឯក សារ៉ាត ប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ ខណ្ឌដូនពេញ
២-លោកស្រី ពៅ សុជាតិ ប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ ខណ្ឌទួលគោក
៣-លោកស្រី ហួត ចណ្ណី អនុប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ ខណ្ឌ៧មករា
៤-លោកស្រី អ៊ាត់ ពេជ្រសុគញ្ញា កម្មសិក្សាគម្រោងសិទ្ធិទទួលបានយុត្តិធម៌
៥-លោកស្រី ហេង ស៊ីណេត ជំនួយការមណ្ឌលសេវាកម្មយុត្តិធម៌ ខណ្ឌដូនពេញ
៦-លោកស្រី សុខ ធីដា មន្ត្រីកម្មសិក្សា
៧-លោកស្រី កែវ ទលគ្ន កម្មសិក្សាមណ្ឌលសេវាកម្មយុត្តិធម៌ ខណ្ឌឫស្សីកែវ
៨-លោក ម៉ែន ផាន់ណារិទ្ធិ មន្ត្រីកម្មសិក្សា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៥៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៦អនក្រ.បកចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ០៨អនក្រ.ប.កចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាលនិង បណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### សម្រេច

**មាត្រា១ :** ប្រគល់ភារកិច្ចជូនលោក **សេខ សុទ្ធី** ជាអគ្គនាយករងរដ្ឋបាល ជំនួសលោក **លី សំអាន** ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ។

**មាត្រា២:** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនមន្ត្រីសង្ឃខេត្ត និងមន្ត្រីសង្ឃគ្រប់ស្រុក ក្រុង នៃខេត្តកណ្តាល ចំនួន៩៥អង្គ ដែលមានព្រះគុណបំណាច់ និងស្នាព្រះហស្តល្អ បានបំពេញកិច្ចការជាប្រយោជន៍ ដើម្បីវិស័យព្រះពុទ្ធសាសនា និងវិស័យអាណាចក្រ ស្របតាមគោលនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាល ដូចមានរាយព្រះនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ព្រះឋានចារី | អ៊ុក | ថុល | ក្រុងតាខ្មៅ |
| ២-ព្រះគ្រូសេដ្ឋានុរក្ខិតញ្ញាណ | សៀម | ចាសនា | ក្រុងតាខ្មៅ |
| ៣-ព្រះគ្រូសង្ឃានុរក្ខវង្សា | ឡាច | ប៊ូរ៉ាត | ក្រុងតាខ្មៅ |
| ៤-ព្រះគ្រូធម្មចារោ | យឹម | ស្តា | ក្រុងតាខ្មៅ |
| ៥-ព្រះគ្រូធម្មជានោ | រស់ | សុភ័ណ្ឌ | ក្រុងតាខ្មៅ |
| ៦-ព្រះគ្រូវិសារទវង្សា | ស៊ូ | សារ៉េត | ក្រុងតាខ្មៅ |
| ៧-ព្រះគ្រូសង្ឃមុនី | ស្រេច | ស្រ៊ន | ក្រុងតាខ្មៅ |
| ៨-ព្រះមហា | ស្រី | ចឹម | ក្រុងតាខ្មៅ |
| ៩-ព្រះមហា | សុន្ទរ៍ | ចន្ទថន | ក្រុងតាខ្មៅ |
| ១០-ព្រះមហា | ភិល | ចន្ទថន | ក្រុងតាខ្មៅ |
| ១១-ព្រះតេជគុណ | ស៊ើច | កុសល | ក្រុងតាខ្មៅ |
| ១២-ព្រះតេជគុណ | ទិក | គក | ក្រុងតាខ្មៅ |
| ១៣-ព្រះតេជគុណ | ព្រុំ | ខុន | ក្រុងតាខ្មៅ |
| ១៤-ព្រះតេជគុណ | នូ | សុភាន | កៀនស្វាយ |
| ១៥-ព្រះតេជគុណ | យុច | កុសល | ស្រុកកៀនស្វាយ |
| ១៦-ព្រះតេជគុណ | យ៉ាន់ | វណ្ណធឿន | ស្រុកកៀនស្វាយ |

| | | | |
|---|---|---|---|
| ១៧-ព្រះតេជគុណ | ស៊ុច | សុគ៌ន្ធ | ស្រុកលើកដែក |
| ១៨-ព្រះតេជគុណ | កែច | យឹម | ស្រុកលើកដែក |
| ១៩-ព្រះតេជគុណ | ឆឿន | ម៉ុនលី | ស្រុកលើកដែក |
| ២០-ព្រះតេជគុណ | ភោគ | រស់ | ស្រុកល្វាឯម |
| ២១-ព្រះតេជគុណ | គឿន | សាន | ស្រុកល្វាឯម |
| ២២-ព្រះតេជគុណ | ហ៊ុម | សេកលីមហេង | ស្រុកល្វាឯម |
| ២៣-ព្រះតេជគុណ | សុខ | សុគន្ធា | ស្រុកល្វាឯម |
| ២៤-ព្រះតេជគុណ | ភង | ហឿន | ស្រុកខ្សាច់កណ្តាល |
| ២៥-ព្រះតេជគុណ | សឿន | សាន | ស្រុកខ្សាច់កណ្តាល |
| ២៦-ព្រះតេជគុណ | ឈឿង | សារឿន | ស្រុកខ្សាច់កណ្តាល |
| ២៧-ព្រះតេជគុណ | យឿន | យ៉ន | ស្រុកខ្សាច់កណ្តាល |
| ២៨-ព្រះតេជគុណ | លន់ | សុវណ្ណជា | ស្រុកខ្សាច់កណ្តាល |
| ២៩-ព្រះតេជគុណ | អ៊ុម | សុគ៌ស្ត | ស្រុកខ្សាច់កណ្តាល |
| ៣០-ព្រះតេជគុណ | ឆាន | សំអឿន | ស្រុកខ្សាច់កណ្តាល |
| ៣១-ព្រះតេជគុណ | យួន | សំអុល | ស្រុកមុខកំពូល |
| ៣២-ព្រះតេជគុណ | ជា | សំអុន | ស្រុកមុខកំពូល |
| ៣៣-ព្រះតេជគុណ | ម៉ក់ | សុខន | ស្រុកមុខកំពូល |
| ៣៤-ព្រះតេជគុណ | សុខ | កុយ | ស្រុកមុខកំពូល |
| ៣៥-ព្រះគ្រូសោធនឧត្តម | នៅ | ដារ៉ា | ស្រុកស្អាង |
| ៣៦-ព្រះតេជគុណ | ពៅ | តុលា | ស្រុកស្អាង |
| ៣៧-ព្រះតេជគុណ | សែម | ឈឿម | ស្រុកស្អាង |
| ៣៨-ព្រះតេជគុណ | ស៊ិន | សារី | ស្រុកស្អាង |
| ៣៩-ព្រះតេជគុណ | ឡុង | ចែម | ស្រុកកោះធំ |
| ៤០-ព្រះតេជគុណ | ឡុយ | សារិន | ស្រុកកោះធំ |
| ៤១-ព្រះតេជគុណ | ឆាន | សារិទ្ធ | ស្រុកកោះធំ |
| ៤២-ព្រះតេជគុណ | មៀត | គន្ធា | ស្រុកកណ្តាលស្ទឹង |
| ៤៣-ព្រះតេជគុណ | ម៉ុត | សោភ័ណ្ឌ | ស្រុកកណ្តាលស្ទឹង |
| ៤៤-ព្រះតេជគុណ | ឡាយ | លីម៉េង | ស្រុកកណ្តាលស្ទឹង |
| ៤៥-ព្រះតេជគុណ | ឯម | សុហ៊ីយា | ស្រុកកណ្តាលស្ទឹង |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលនៃគណៈអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធ ផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងកញ្ញា **ចាន់ បូរ៉ុម** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីទី ២ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំចក្រភពអង់គ្លេស ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមាន ចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោកស្រី **អ៊ុង បូផល** បច្ចុប្បន្នប្រធាននាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមាន ចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧ - អនក្រ . តត

# អនុក្រឹត្យ

## ស្តីពី

## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់លោក **ខួន សុជាតិ** បច្ចុប្បន្នទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៨. អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែល ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១៥១អនក្រ.បកចុះថ្ងៃទី០៦ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើត ខុទ្ទកាល័យឧបនាយក រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា ១ ._**

ត្រូវបានបញ្ចប់មុខតំណែងលោក **ខាំ គីមលី** ពីជំនួយការឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី។

**មាត្រា ២ ._**

